ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ០៦ រោច ខែ បុស្ស ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីកិច្ចពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម YAMAMOTO Kozo សមាជិកសភាតំណាងរាស្ត្រប្រទេសជប៉ុន

នាព្រឹកថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជួបពិភាក្សាការងារជាមួយឯកឧត្តម YAMAMOTO Kozo សមាជិកសភាតំណាងរាស្ត្រប្រទេសជប៉ុន នាឱកាសដែលឯកឧត្តមអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។ ទស្សនកិច្ចរបស់ឯកឧត្តម YAMAMOTO Kozo មានគោលបំណងសិក្សាស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍ជាមួយភាគីកម្ពុជាលើការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ជាពិសេស លើការប្រើប្រាស់បច្ចេកវិទ្យាថ្មីក្នុងវិស័យធនាគារ ។

នៅក្នុងជំនួបពិភាក្សានោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះឯកឧត្តម YAMAMOTO Kozo សមាជិកសភាតំណាងរាស្ត្រប្រទេសជប៉ុន ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ឆ្លៀតពីការបំពេញការងារដ៏មមាញឹកនៅក្នុងប្រទេសជប៉ុន មកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានគូសរំលេចពីគុណបំណាច់ដ៏ឧត្តុង្គឧត្តមរបស់រដ្ឋាភិបាល និងប្រជាជនជប៉ុន ចំពោះរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ចាប់តាំងពីការជួយដល់ដំណើរការកសាងសន្តិភាពរហូតដល់ការអភិវឌ្ឍលើគ្រប់វិស័យ ។ ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា និងជប៉ុន ត្រូវបានពង្រឹង និងពង្រីកឥតឈប់ឈរ ហើយបាននាំមកនូវសមិទ្ធផលប្រកបដោយផ្លែផ្កាជាច្រើនអនេក ជាពិសេស ក្នុងក្របខ័ណ្ឌជំនួយបច្ចេកទេស ហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន ។ ទន្ទឹមនេះ លំហូរវិនិយោគផ្ទាល់ពីប្រទេសជប៉ុនក៏មានសន្ទុះកើនឡើងផងដែរ ដែលបានជួយបង្កើតការងារ, ផ្ទេរបទពិសោធន៍ និងចំណេះដឹង, ព្រមទាំងបានរួមចំណែក កាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។

ឯកឧត្តម YAMAMOTO Kozo បានលើកឡើងថា ប្រទេសកម្ពុជាសម្រេចបានការអភិវឌ្ឍយ៉ាងឆាប់រហ័ស និង មានកំណើនសេដ្ឋកិច្ចខ្ពស់ ហើយវិស័យហិរញ្ញវត្ថុនៅកម្ពុជាក៏មានការលូតលាស់គួរឲ្យកត់សម្គាល់ផងដែរ ។ ឯកឧត្តម បានលើកឡើងពីប្រវត្តិនៃការកសាងសេដ្ឋកិច្ចប្រទេសជប៉ុន ការធ្វើកំណែទម្រង់វិស័យហិរញ្ញវត្ថុ និងការជំរុញឲ្យអនុវត្តមធ្យោបាយ ទូទាត់ដែលមិនប្រើក្រដាសប្រាក់តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ។ ដើម្បីលើកទឹកចិត្តឲ្យវិនិយោគិនជប៉ុនមកដាក់ទុនវិនិយោគនៅកម្ពុជាឲ្យបានកាន់តែច្រើនឡើងថែមទៀត ឯកឧត្តមតំណាងរាស្ត្រជប៉ុនបានស្នើឲ្យភាគីទាំងពីរ កម្ពុជា និងជប៉ុន ចុះកិច្ចព្រមព្រៀងស្តីពីការជៀសវាងការយកពន្ធត្រួតគ្នាឲ្យបានឆាប់ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានជម្រាបជូនឯកឧត្តមតំណាងរាស្ត្រជប៉ុន YAMAMOTO Kozo អំពីគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានចក្ខុវិស័យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។ ក្នុងវិស័យហិរញ្ញវត្ថុ រាជរដ្ឋាភិបាលកម្ពុជា មានក្របខ័ណ្ឌគោលនយោបាយរយៈពេលវែងស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ដែលជំរុញឱ្យប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន ។ រាជរដ្ឋាភិបាលកម្ពុជា ក៏កំពុងអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ ។ ទន្ទឹមនេះ, ធនាគារជាតិនៃកម្ពុជា បានបង្កើតប្រព័ន្ធបាគង ដែលជាប្រព័ន្ធទូទាត់តាមបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពនៃការទូទាត់ដោយមិនប្រើក្រដាសប្រាក់ ។

ដោយឡែក ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងស្តីពីការជៀសវាងការយកពន្ធត្រួតគ្នាជាមួយប្រទេសជប៉ុន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានជំរុញឱ្យក្រុមការងារបច្ចេកទេសពាក់ព័ន្ធនៃប្រទេសទាំងពីរ បន្តចរចាជាមួយគ្នាបន្ថែមទៀត ដើម្បីរកឱ្យឃើញនូវដំណោះស្រាយរួមសម្រាប់ឈានទៅចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះនាពេលឆាប់ៗខាងមុខ ។

ឆ្លៀតក្នុងឱកាសនោះដែរ, ជាថ្មីម្តងទៀត, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនជប៉ុន ដែលបាននិងបន្តជួយឧបត្ថម្ភគាំទ្រដល់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ហើយបានរួមវិភាគទានដ៏ថ្លៃថ្លាដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ៕